# ស្ថានភាពអតិផរណានៅខែកុម្ភៈ ឆ្នាំ២០១៩

## ក/ អតិផរណាក្នុងប្រទេស

តាមប្រភពទិន្នន័យផ្លូវការពីវិទ្យាស្ថានជាតិស្ថិតិ (NIS) បានបង្ហាញថា នៅខែកុម្ភៈ ឆ្នាំ២០១៩នេះ ជារួម សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់គ្រប់មុខនៅរាជធានីភ្នំពេញ ***មានការកើនឡើង ០,៨% បើធៀបនឹងខែមុន និង ១,៥% បើធៀបនឹងខែកុម្ភៈឆ្នាំមុន។***

នៅខែកុម្ភៈ ឆ្នាំ២០១៩នេះ សន្ទស្សន៍ថ្លៃក្រុមទំនិញស្ទើរតែទាំងអស់ មានការកើនឡើងបើធៀបនឹងខែមករាកន្លងទៅ។ លើសពីនេះ បើប្រៀបធៀបនឹងខែកុម្ភៈដូចគ្នាឆ្នាំមុន សន្ទស្សន៍ថ្លៃក្រុមទំនិញភាគច្រើនក៏មានការកើនឡើងដូចគ្នា ក្នុងនោះ សន្ទស្សន៍ថ្លៃភោជនីយដ្ឋានកើនឡើង ៧,២% សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់បានកើនឡើង ៦,៤% (ស្រាកើន ៦,១% និងថ្នាំជក់ កើន ៨,០%) សម្លៀកបំពាក់និងស្បែកជើងកើនឡើង ៣,៦% (វត្ថុធាតុដើមសម្លៀកបំពាក់ កើន ០,៩% និងសម្លៀកបំពាក់គ្រប់ប្រភេទ កើន ៤,៦%) និងផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀតកើនឡើង ១,២% (ឧស្ម័ន កើន ៥,៤% និង ឥន្ធនៈរឹង កើន ២,២%)។ *ចំណែកឯ សន្ទស្សន៍ថ្លៃការដឹកជញ្ជូននៅតែបន្តធ្លាក់ចុះ ៣,៩% ក្នុងនោះ សន្ទស្សន៍ថ្លៃប្រេងសាំងធម្មតាធ្លាក់ចុះ ១៤,៣% និងសន្ទស្សន៍ថ្លៃប្រេងម៉ាស៊ូតធ្លាក់ចុះ ៣,៨%*។ ជាក់ស្តែង ប្រេងសាំងធម្មតាលក់រាយលើទីផ្សារ ក្នុងខែមករា ឆ្នាំ២០១៩ ថ្លៃ ៣.៤០០ រៀល/លីត្រ ទាបជាងក្នុងខែដូចគ្នាឆ្នាំ២០១៨ ថ្លៃ ៣.៨៥០ រៀល/លីត្រ *(ប្រភព÷ Ministry of Commerce)*។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **+០,៨** | **+២,០** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +០,៧ | +២,២ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +០,៣ | +៦,៤ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | +០,៩ | +៣,៦ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | +០,៨ | +១,២ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | +០,៣ | +១,៦ |
| ៦-សុខាភិបាល | +០,២ | +២,៣ |
| ៧-ការដឹកជញ្ជូន | +១,៦ | -៣,៩ |
| ៨-គមនាគមន៍ | +០,១ | -០,៤ |
| ៩-ការកំសាន្ត និងវប្បធម៌ | -០,១ | +០,៩ |
| ១០-ការសិក្សា | ០,០ | +០,៤ |
| ១១-ភោជនីយដ្ឋាន | +១,៩ | +៧,២ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +១,១ | +១,៣ |

| តារាង ២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបនឹងខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | ២០១៩ | | ២០១៨ | ២០១៩ | |
| | ធ្នូ | មករា | កុម្ភៈ | ធ្នូ | មករា | កុម្ភៈ |
| អង្ករ | +០,៣ | +០,២ | +០,៦ | +២,៤ | +២,៦ | +២,៩ |
| សាច់គោ | +០,២ | +០,៤ | +០,២ | +១,២ | +២,១ | +១,៦ |
| សាច់មាន់ | +០,៤ | +០,៥ | ០,០ | +៣,២ | +៤,០ | +២,៩ |
| សាច់ទា | -០,៣ | +០,៦ | +០,៦ | +១,៥ | +២,២ | +៣,០ |
| សាច់ជ្រូក | -០,៣ | +០,៧ | +០,៦ | +១,៥ | +១,៧ | +២,០ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | +០,១ | +០,២ | +០,២ | +២,៣ | +២,៦ | +២,៤ |
| ក្នុងនោះត្រីស្រស់ | +០,១ | ០,០ | ០,០ | +១,៨ | +២,០ | +១,៦ |
| ផ្លែឈើ | -០,៣ | -០,៧ | +១,៣ | +១,៨ | +១,៧ | +១,២ |
| ផ្លែឈើស្រស់ | -០,៣ | -០,៦ | +១,៤ | +១,៧ | +១,៦ | +១,២ |
| បន្លែ | -០,៨ | -១,០ | +១,៤ | +៣,៥ | +២,៧ | +៣,៩ |
| បន្លែជាស្លឹក | -១,០ | -១,១ | +១,៤ | +៤,៩ | +៥,១ | +៦,៥ |
| បន្លែជាផ្លែ | -១,២ | -១,៥ | +២,២ | +៥,៤ | +២,៣ | +៣,៨ |

## ១/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | |
|---|---|---|---|---|
| ប្រទេស | ២០១៨ | | ២០១៩ | |
| | វិច្ឆិកា | ធ្នូ | មករា | កុម្ភៈ |
| ប្រទេសកម្ពុជា | 2.5 | 1.6 | 1.5 | 2.0 |
| ប្រទេសវៀតណាម | 3.5 | 3.0 | 2.6 | 2.6 |
| ប្រទេសថៃ | 0.9 | 0.4 | 0.3 | 0.7 |
| ប្រទេសម៉ាឡេស៊ី | 0.2 | 0.2 | -0.7 | -0.4 |
| ប្រទេសឥណ្ឌូនេស៊ី | 3.2 | 3.1 | 2.8 | 2.6 |
| ប្រទេសហ្វីលីពីន | 6.0 | 5.1 | 4.4 | 3.8 |
| ប្រទេសចិន | 2.2 | 1.9 | 1.7 | 1.5 |
| ប្រទេសកូរ៉េខាងត្បូង | 2.0 | 1.3 | 0.8 | 0.5 |
| ប្រទេសជប៉ុន | 0.8 | 0.3 | 0.2 | 0.2 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

## <u>កំណត់សម្គាល់</u>

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៨ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*